# ការសំភាសន៍របសម៉ាក់យាយ ញៀន ធឿង

កៈ អ្នកដែរសំភាសន៍គេមាន ជាងស៊ីអ៊ារ ខៈ អ្នកដែរអោយគេសំភាសន៍ ញៀន ធឿង

## <u>ការសង្ខេបប្រវត្តិរបស់ម៉ាក់យាយ ញៀន ធឿង</u>

ម៉ាក់យាយ ញៀន ធឿង មានអាយុ ម៉ាក់យាយ ញៀន ធឿង មានភេទស្រី ម៉ាក់យាយ ញៀន ធឿង មានទីលំនៅបច្ចុប្បន្ននៅភូមិ។

កៈ
ចឹងជាដំបូងខ្ញុំសូមអរគុណច្រើនម៉ាក់យាយដែរបានអោយខ្ញុំសំភាសន៍ពីប្រវត្តិរបស់ម៉ាក់យាយ ហើយការសំភាសន៍
នេះត្រូវបានរៀបចំឡើងដោយសកលវិទ្យាល័យមួយដែរនៅអាមេរិចដែរមានឈ្មោះថាBYU ហើយដោយសារតែសកលវិទ្យាល័យមានគោលបំណងចង់រក្សាពីប្រវត្តិប្រជាជនខ្មែរដើម្បីទុកអោយកូនចៅ ជំនាន់ក្រោយៗពួកគាត់បានស្គាល់ពីប្រវត្តិរបស់ឳពុកម្ដាយ នឹងប្រវត្តិរបស់ដូចតា ចឹងនៅពេលដែរខ្ញុំបាន
សំភាសន៍ម៉ាក់យាយហើយខ្ញុំនឹងដាក់ការសំភាសន៍មួយនេះទៅក្នុងវេបសាយរបស់សាលាដែរមានឈ្មោះថា www.cambodianoralhistories.byu.edu ចឹងហាសម៉ាក់យាយ
ចឹងតើម៉ាក់យាយយល់ព្រមដើម្បីអោយខ្ញុំដាក់ការសំភាសន៍
មួយនេះទៅក្នុងវេបសាយរបស់សាលាដែរទេម៉ាក់យាយ?

ខៈ អើរនឹង

កៈ អត់អីទេណាម៉ាក់យាយចឹងសំរាប់ខ្ញុំជាអ្នកដែរសំភាសន៍ម៉ាក់យាយខ្ញុំមានឈ្មោះថា ជាង ស៊ីអ៊ារ ហើយថ្ងៃខែដែរខ្ញុំសំភាសន៍មួយនេះត្រូវបាន ធ្វើឡើងនៅថ្ងៃទី21?

ខៈ ថ្ងៃនឹងគឺជាថ្ងៃពុធ

កៈ នៅថ្ងៃទី21 ខែ3 ឆ្នាំ2018 ហើយបានធ្វើឡើងនៅភូមិបឹងកំប្លោក សង្កាត់ចាក់អង្រែលើ នៅខ័ណ្ឌចំការមននៅរាជធានីភ្នំពេញ
ចឹងសំរាប់ម៉ាក់យាយឈ្មោះរបស់ម៉ាក់យាយនឹងមានឈ្មោះអីគេដែរម៉ាក់យាយ?

ខៈ ខ្ញុំឈ្មោះធឿង

កៈ ប៉ុន្តែឈ្មោះពេញរបស់ម៉ាក់យាយហាស?

ខៈ ឈ្មោះ ធឿងនឹងហើយ

កៈ ឈ្មោះមុំធឿងហោសម៉ាក់យាយ?

ខៈ ទេឈ្មោះញៀន ធឿង នឹងត្រកូលឈ្មោះឪ

កៈ ឈ្មោះ ញៀន ធឿង
ចុះម៉ាក់យាយកាលពីក្មេងនឹងមាននរណាហៅឈ្មោះម៉ាក់យាយអីផ្សេងទេដែរ ម៉ាក់យាយ?

ខៈ គ្មានទេនឹង

កៈ ចឹងមានតែមួយនឹងទេណាម៉ាក់យាយ?

ខៈ ចា៎!នឹងហើយ

កៈ ចុះម៉ាក់យាយមានឈ្មោះហៅក្រៅដែរទេម៉ាក់យាយ?

ខៈ អត់មានទេនឹងមានឈ្មោះមួយនឹង

កៈ ចឹងអត់មានទេហោសម៉ាក់យាយ
ចុះម៉ាក់យាយសព្វថ្ងៃនឹងម៉ាក់យាយអាយុប៉ុន្មានដែរទៅម៉ាក់យាយ?

ខៈ ខ្ញុំអាយុហុកជាងនឹង

កៈ ចុះអាយុហុកប៉ុន្មានដែរទៅម៉ាក់យាយ?

ខៈ ខ្ញុំអាយុ63ឆ្នាំ

កៈ ចឹងម៉ាក់យាយអាយុ63ឆ្នាំ
ចុះម៉ាក់យាយកើតនៅថ្ងៃខែឆ្នាំណាដែរម៉ាក់យាយមានចងចាំទេ?

ខៈ ខ្ញុំអត់ដឹងផងម៉ែនឹង

កៈ ប៉ុន្តែថ្ងៃខែនឹងម៉ាក់យាយអត់ចងចាំដែរហោសម៉ាក់យាយ?

ខៈ អត់មានទេ

កៈ ចុះឆ្នាំម៉ាក់យាយចាំឆ្នាំអីគេទេដូចថានៅឆ្នាំប៉ុន្មានម៉ាក់យាយមានចងចាំឆ្នាំប៉ុន្មានដែរទេម៉ាក់យាយ?

ខៈ ខ្ញុំអត់ដឹងទេនេះ

កៈ ចឹងម៉ាក់យាយកើតនៅឆ្នាំ1955នៅជំនាន់សាធារណៈរដ្ឋមែនទេម៉ាក់យាយ?

ខៈ អើរនឹងហើយ

កៈ ចុះឆ្នាំច័ន្ទគតិនឹងម៉ាក់យាយមានដឹងថាម៉ាក់យាយឆ្នាំអីគេដែរទេ លក្ខណៈថាឆ្នាំជូត ឆ្លូវ ខាល ថោះដែរចឹងហាស?

ខៈ ឆ្នាំចនឹង ខ្ញុំឆ្នាំច

កៈ ចឹងម៉ាក់យាយឆ្នាំច ម៉ាក់យាយចឹងម៉ាក់យាយកើតនៅណាដែរម៉ាក់យាយ?

ខៈ ខ្ញុំកើតនៅសំរោងវាល

កៈ ចុះម៉ាក់យាយកើតនៅសំរោងវាលនឹងនៅណាវិញទៅម៉ាក់យាយ?

ខៈ នៅក្បែរតាផុចនឹងហាស

កៈ នៅខេត្តអីគេដែរម៉ាក់យាយ មួយនឹងនៅខេត្តអីគេដែរម៉ាក់យាយ?
ខៈ នៅខេត្តអីទេនេះ បើស្រុកនឹងនៅស្រុកមេសាងហើយ នឹងខេត្តព្រៃវែងហើយនឹង

កៈ នៅស្រុកមេសាងនៅ ខេត្តព្រៃវែង ចុះឃុំអីគេដែរម៉ាក់យាយ?

ខៈ នៅភូមិយាយផុច

កៈ ភូមិយាយផុច ចុះឃុំវិញម៉ាក់យាយមានស្គាល់ដែរទេ?

ខៈ អូយខ្ញុំមិនសូវដឹងទេនឹង

កៈ អូ៎!បាទអត់អីទេម៉ាក់យាយ
ចឹងសំរាប់ម៉ាក់យាយនឹងមានបងប្អូនចំនួនប៉ុន្មាននាក់ដែរម៉ាក់យាយ?

ខៈ ខ្ញុំមានបងប្អូនចំនួន7នាក់

កៈ ចឹងម៉ាក់យាយមាន7នាក់ហោសម៉ាក់យាយ
ចុះម៉ាក់យាយជាកូនទីប៉ុន្មានដែរទៅម៉ាក់យាយ?

ខៈ ខ្ញុំជាកូនទី4នឹង

កៈ ម៉ាក់យាយជាកូនទី4 ចុះមានស្រីប៉ុន្មាននាក់ នឹងប្រុសប៉ុន្មាននាក់ដែរម៉ាក់យាយ?

ខៈ ស្រីមានប៉ុន្មានទេនេះស្រីដូចជាមាន3-4នាក់នឹង មានប្រុស7នាក់

កៈ អ៊ូ!ប្រុសមាន7នាក់នាក់ចឹងមានន័យថា10នាក់ហើយចឹងម៉ាក់យាយ?

ខៈ អើរនឹង

កៈ ចឹងម៉ាក់យាយជាកូនទៅ4នឹង?

ខៈ អើរ.........!!

កៈ ប៉ុន្តែម៉ាក់យាយមានចងចាំឈ្មោះគាត់ដែរទេម៉ាក់យាយ
ថាពួកគាត់មានឈ្មោះអីគេខ្លះដែរ?

ខៈ មើលឈ្មោះអាមយ អាម៉ុង អាហាក់

កៈ ហើយបានម៉ាក់យាយទី4?

ខៈ អើរ

កៈ ចុះទី5វិញឈ្មោះអីគេដែរម៉ាក់យាយ?

ខៈ ចុះបងគេបង្អស់នឹងឈ្មោះថិន
គេបញ្ជូនទៅលិចហោសទៅអាពតស្រួលនឹងស្លាប់ហើយមើលទៅនឹង

កៈ ចុះបងទី2នឹងមានឈ្មោះអីគេដែរទៅម៉ាក់យាយ?
ខៈ បងទី2នឹងមានឈ្មោះមយ

កៈ គាត់ឈ្មោះមយ ចុះបងទី3ម៉ាក់យាយ?

ខៈ ឈ្មោះអាម៉ុង

កៈ ឈ្មោះម៉ុង ទី4នឹងម៉ាក់យាយចុះទី5វិញម៉ាក់យាយ?

ខ៖ ៣៧គេនឹងឈ្មោះហាក់

ក៖ ៣៧គេនឹងឈ្មោះហាក់ណាម៉ាក់យាយ?

ខ៖ ប៉ុន្តែឥឡូវនឹងស្លាប់ហើយនឹង

ក៖ អូ!ចឹងស្លាប់ទាំងអស់មែនម៉ាក់យាយ ចឹងនៅតែម៉ាក់យាយមួយទេហោសម៉ាក់យាយ?

ខ៖ អើរនឹងហើយ

ក៖ ប៉ុន្តែពួកគាត់ស្លាប់ដោយសារអីដែរ?

ខ៖ ថាសង្ឃឹមប្អូននឹងប៉ុន្តែឥឡូវនឹងប្អូនទៅបាត់ហើយនឹង

ក៖ ពួកគាត់កើតអីបានពួកគាត់ស្លាប់ដែរម៉ាក់យាយដឹងទេ?

ខ៖ វាមកធ្វើសំណង់នឹងវាខ្យល់

ក៖ ចឹងមានន័យថាបងប្អូនរបស់ម៉ាក់យាយនឹងមាននៅសល់តែម៉ាក់យាយមួយទេ?

ខ៖ នឹងហើយនៅសល់តែខ្ញុំមួយទេនឹង

ក៖ អូ!ប៉ុន្តែម៉ាក់យាយឥឡូវនឹងនៅស្រុកមែនទេម៉ាក់យាយ?

ខ៖ នៅចូលឆ្នាំនឹងគេអោយទៅស្រុកនឹងហើយ

ក៖ អូ!ទៅនៅស្រុកវិញ?

ខ៖ ទៅលេងស្រុកនឹងចូលឆ្នាំចូលអីនឹង

ក៖ ដល់ពេលដែរចប់ហើយនឹងបានម៉ាក់យាយមកនៅជាមួយកូនវិញចឹងទៅ?

ខ៖ នឹងហើយ

ក៖
ចឹងមានន័យថាសព្វថ្ងៃនឹងធំម៉ាក់យាយមកនៅជាមួយកូនហើយណាម៉ាក់យាយឈប់ទៅនៅស្រុក ហើយណាម៉ាក់យាយ?

ខ៖ នឹងហើយ

ក៖  បាទចឹងសំរាប់ម៉ាក់យាយមានចងចាំសាច់រឿងអីកាលពីគាត់នៅរស់កាលពីម៉ាក់យាយនៅក្មេងៗៗ ហាសធ្លាប់បានលេងអីជាមួយគ្នាដែរទេដូចថាលេងឡឹកបាយឡ លេងបិទពួនអីចឹងហាស?

ខ៖  អត់ដែរផងនឹង

ក៖  អត់ដែរទេប៉ុន្តែធ្លាប់ទៅស្រែជាមួយគ្នាដែរទេម៉ាក់យាយ?

ខ៖  ទៅស្រែនឹងប្រឹងតែច្រូតនឹងពូ

ក៖

អូ៎!ចឹងហោសម៉ាក់យាយប៉ុន្តែយើងធ្លាប់បានលេងអីជាមួយបងប្អូនរបស់យើងនឹងដែរយើងចាំហាស ម៉ាក់យាយមានធ្លាប់លេងអីកាលពីយើងនៅក្មេងៗៗអាយុ4-5ឆ្នាំអីនឹងហាស?

ខ៖  អត់ដែរផងនឹង

ក៖ ចឹងអត់ដែរទេណាម៉ាក់យាយ?

ខ៖  អើរនឹងហើយ

ក៖  ចុះម៉ាក់យាយគិតថាធ្លាប់ទៅស្ទូងត្រី រឺមួយក៏ចាប់ក្តាមអីជាមួយគាត់ដែរទេ?

ខ៖  បើទៅអូសត្រីអូសអីនឹងចេះតែទៅហើយនឹង

ក៖  ចឹងធ្លាប់ទៅណាម៉ាក់យាយណា?

ខ៖  នឹងហើយ

ក៖

ចុះម៉ាក់យាយបើនិយាយពីចូលចិត្តវិញតើម៉ាក់យាយចូលចិត្តលេងអីគេដែរជាមួយបងប្អូនរបស់ ម៉ាក់យាយដែរនឹង?

ខ៖  ចូលចិត្តលេងទោងអីវិននឹងហាស

ក៖  ចូលចិត្តលេងទោងហោសម៉ាក់យាយ?

ខ៖  នឹងហើយកាលពីនៅតូចៗៗនឹងហាស

កៈ  បាទម៉ាក់យាយ ចុះម៉ាក់យាយចូលចិត្តលេងបាយខំ នឹងលេងកូនប៉ែងអីទេម៉ាក់យាយ?

ខៈ  អត់ដែរទេ

កៈ  ចឹងអត់ដែរទេណាម៉ាក់យាយ?

ខៈ  នឹងហើយ

កៈ  ចុះសំរាប់ឪពុករបស់ម៉ាក់យាយនឹងគាត់ឈ្មោះអីគេដែរម៉ាក់យាយ?

ខៈ  គាត់ឈ្មោះតាញៀន

កៈ  ចឹងគាត់ឈ្មោះតាញៀន អ្ហូប៉ុន្តែដឹងថាគាត់ឥឡូវនឹងគាត់អាយុប៉ុន្មានដែរទេម៉ាក់យាយ?

ខៈ  មិនដឹងទេគាត់ស្លាប់ហើយនឹងគេបញ្ជូនទៅស្រុកលិចអស់ហើយនឹង

កៈ  អ្ហុំ!ចឹងហោសម៉ាក់យាយ?

ខៈ គេបញ្ជូនទៅទាំងអស់នឹងហាស

កៈ  គាត់ស្លាប់តាំងពីពលពតហោស?

ខៈ  ម៉ែគាត់ឈឺទាស់

កៈ  ប៉ុន្តែរហូតមកដល់ឥឡូវនឹងម៉ាក់យាយអត់ដឹងថាគាត់អាយុប៉ុន្មានដែរទេ?

ខៈ  ខ្ញុំអត់ដឹងផងនឹង

កៈ  ប៉ុន្តែគាត់កើតនៅណាដែរឪពុករបស់ម៉ាក់យាយហាស?

ខៈ  នៅគៀនភ្លើងហោសឆ្ងាយណាស់

កៈ  នៅគៀនភ្លើងនឹងនៅខេត្តណាវិញម៉ាក់យាយ?

ខៈ  គៀនភ្លើងនៅនោះៗ

កៈ  នៅណាវិញទៅម៉ាក់យាយ?

ខៈ  គៀនភ្លើងនឹងនៅជើងហោស

កៈ  ប៉ុន្តែនៅខេត្តអីគេដែរម៉ាក់យាយមានដឹងទេ?

ខ៖ នៅដូងគឹង

ក៖ នៅដូងគឹងប៉ុន្តែនៅខ្មែរយើងវីមួយក៏នៅណាដែរម៉ាក់យាយ?

ខ៖
ខ្ញុំអត់ដឹងទេខ្ញុំកើតឡើងមកនឹងអត់ឃើញឪពុករបស់ខ្ញុំទេឪពុករបស់ខ្ញុំគាត់ទៅបាត់ហើយនឹង

ក៖ អូ!ចុះម្តាយរបស់ម៉ាក់យាយនឹងគាត់ឈ្មោះអីគេដែរម៉ាក់យាយ?

ខ៖ ម្តាយរបស់ខ្ញុំឈ្មោះយាយថៃ នឹងតាញៀន

ក៖ អូ!ចឹងគាត់ឈ្មោះយាយថៃ ប៉ុន្តែពួកគាត់ស្លាប់ទាំងពីរនាក់ហោសម៉ាក់យាយ?

ខ៖ ពួកគាត់ស្លាប់ទាំងអស់ហើយនឹង

ក៖ ប៉ុន្តែម្តាយរបស់ម៉ាក់យាយនឹងម៉ាក់យាយមានដឹងទេ?

ខ៖ គាត់កើតនៅសំរោងវាល

ក៖ គាត់កើតនៅសំរោងវាលនៅខេត្តព្រៃវែងនឹងហោសម៉ាក់យាយ?

ខ៖ នឹងហើយ

ក៖
អូ!បាទចឹងសំរាប់កាលពីឪពុករបស់ម៉ាក់យាយនៅរស់នឹងកាលពីបានម្តាយរបស់ម៉ាក់យាយនឹង គាត់ធ្វើអីគេដែរសំរាប់ចិញ្ចឹមជីវិតដែរម៉ាក់យាយ ចិញ្ចឹមគ្រួសារហោស?

ខ៖ គាត់ស្ទូង នឹងដក

ក៖ ចឹងគាត់ស្ទូង ដក ប៉ុន្តែគាត់មានធ្លាប់ធ្វើអីផ្សេងទៀតទេម៉ាក់យាយ ដូចថាធ្វើជាជាងសំណង់ចឹង?

ខ៖ គាត់លក់បន្លែលក់អីនឹង

ក៖ អូ!គាត់លក់បន្លែដែរហោសម៉ាក់យាយ?

ខ៖ គាត់លក់ល្ពៅអាល្ពៅធំៗៗនឹង

កៈ អូ៎!បាទប៉ុន្តែគាត់មានធ្លាប់ធ្វើសំណង់អីទេម៉ាក់យាយ?

ខៈ គាត់មិនដែរទេ

កៈ ចឹងគាត់ទៅធ្វើតែស្រែចំការនឹងលក់ដូរលក់ល្ពៅ នឹងលក់បន្លែណាម៉ាក់យាយ?

ខៈ ប្អូនៗៗនឹងវាធ្វើសំណង់

កៈ បាទម៉ាក់យាយចុះឪពុករបស់ម៉ាក់យាយគាត់កាចរឺមួយក៏ស្លូតដែរម៉ាក់យាយ?

ខៈ គាត់គ្មានកាចទេនឹងគាត់ស្លូតនឹង

កៈ គាត់ស្លូតណាម៉ាក់យាយ?

ខៈ អើរនឹងហើយ

កៈ ចុះម្ដាយរបស់ម៉ាក់យាយនឹងគាត់ធ្វើអីគេដែរសំរាប់ចិញ្ចឹមជីវិតដែរម៉ាក់យាយ?

ខៈ គាត់ធ្វើតែស្មូង នឹងដកនឹង

កៈ អូ៎!គាត់ធ្វើស្មូង នឹងដកដែរហោស?

ខៈ ចា៎!នឹង

កៈ ប៉ុន្តែគាត់មានធ្លាប់លក់ដូរអីដូរឪពុករបស់ម៉ាក់យាយទេ?

ខៈ គ្មានទេនឹង

កៈ ចឹងអត់មានទេណាម៉ាក់យាយ?

ខៈ គាត់នៅតែផ្ទះនឹងទេតែឪនឹងគាត់អ្នកដកលក់ ឪមកទិញនៅឆ្ងាយៗៗណាស់

កៈ បាទចឹងឪពុករបស់ម៉ាក់យាយនឹងគាត់អោយម្ដាយរបស់ម៉ាក់យាយនឹងនៅផ្ទះ?

ខៈ អើរនឹង

កៈ ចឹងនៅចិញ្ចឹមកូនណាម៉ាក់យាយ?

ខៈ ចា៎!!

កៈ អូ៎!បាទចុះម្ដាយរបស់ម៉ាក់យាយនឹងគាត់ស្លូតរឺមួយកាចដែរម៉ាក់យាយ?

ខ៖ ម្តាយរបស់ខ្ញុំនឹងគាត់មិនសូវកាចប៉ុន្មានទេគាត់ល្មម

ក៖ គាត់ល្មមហោស
ចុះម៉ាក់យាយមានចងចាំថាកាលពីម៉ាក់យាយនៅជាមួយឪពុកម្តាយរបស់ ម៉ាក់យាយនឹង ម៉ាក់យាយធ្លាប់មានអនុស្សាវរីយ៍អីជាមួយគ្នាអត់ ធ្លាប់ដាំបាយរឺមួយក៏ទៅស្រែអីជាមួយគ្នាដែរចឹងហាសម៉ាក់យាយ នឹងញ៉ាំបាយជាមួយគ្នាអីចឹងហាស?

ខ៖ បងប្អូននៅជាមួយគ្នាជុំគ្នានឹងមានតែញ៉ាំបាយស្រែនឹងម៉ែយកទៅហូបហើយនឹង

ក៖ ចឹងសប្បាយហាសណាម៉ាក់យាយ?

ខ៖ ចា៎!នឹងហើយ

ក៖
ចុះឪពុករបស់ម៉ាក់យាយនឹងគាត់មានធ្លាប់ប្រាប់ពីប្រវត្តិកាលពីគាត់នៅក្មេងទៅម៉ាក់ទេ?

ខ៖ គាត់មិនដែរប្រាប់ទេ

ក៖ ចឹងគាត់មិនបានប្រាប់អីទេណា?

ខ៖ អើរចឹងគាត់ស្លាប់ហើយនឹងគាត់ឈឺរឹងទៅៗ

ក៖ ប៉ុន្តែគាត់ឈឺអីគេដែរម៉ាក់យាយ?

ខ៖ គាត់ចេះតែទាស់ៗនឹង ទាស់ទុំ

ក៖ ចុះម្តាយរបស់ម៉ាក់យាយគាត់មានធ្លាប់ពីប្រវត្តិកាលពីគាត់នៅក្មេងទៅម៉ាក់យាយទេ?

ខ៖ អើស

ក៖
ម្តាយម៉ាក់យាយហាសគាត់មានធ្លាប់ប្រាប់ពីប្រវត្តិកាលពីគាត់នៅក្មេងទៅម៉ាក់យាយដែរទេ?

ខ៖ គាត់នៅក្មេងនឹងបងប្អូនរបស់គាត់មាន5នាក់

ក៖ ប៉ុន្មានគាត់ធ្វើអីគេដែរចឹងហាសម៉ាក់យាយ?

ខ៖ នឹងហើយ

ក៖ កាលពីគាត់នៅក្មេងនឹងគាត់ធ្វើអីគេដែរទៅម៉ាក់យាយ?

ខ៖ គាត់ដូចថាដើរស៊ីឈ្នួលគេ

ក៖ អូ!បាទចុះយាយតាខាងម្ដាយនឹងម៉ាក់យាយមានស្គាល់ឈ្មោះគាត់ដែរទេ?

ខ៖ អូ!មិនដឹងណាណីទេ

ក៖ ចឹងអត់ចងចាំទេណាម៉ាក់យាយ?

ខ៖ ខ្ញុំអត់ចងចាំទេឆ្ងាយនៅដូនគឹងនឹងនៅសាយចូលហិបនឹងមានអីដឹង

ក៖ ប៉ុន្តែដូចជាពួកគាត់ឈ្មោះអីគេដែរម៉ាក់យាយមានស្គាល់ទេ?

ខ៖ គាត់ស្គាល់ទាន់ភ្លើងទេ?

ក៖ នៅទាន់ភ្លើង?

ខ៖ ទាន់ភ្លើងនៅនោះនៅជើងហោស

ក៖ ខ្ញុំអត់សូវស្គាល់ផងនឹង

ខ៖ នៅឆ្ងាយណាស់

ក៖ ចុះយាយតាខាងឪពុកនឹងម៉ាក់យាយមានស្គាល់ឈ្មោះគាត់ដែរទេចឹង?

ខ៖ មិនស្គាល់ទេអត់ស្គាល់ទេនឹង

ក៖ ចឹងអត់ស្គាល់ទេណាម៉ាក់យាយ?

ខ៖ ខ្ញុំកើតក្រោយតើៗនឹង

ក៖
ម៉ាក់យាយកើតក្រោយទេណាម៉ាកចឹងពួកគាត់កើតនៅណាក៏ម៉ាក់យាយអត់ដឹងដែរណាម៉ាក់យាយ?

ខ៖ នឹងហើយ

កៈ ចឹងដូចជាម៉ាក់យាយមករស់ទីក្រុងភ្នំពេញនឹងយូរនៅម៉ាក់យាយ?

ខៈ មកនៅ3-4ឆ្នាំហើយនឹង

កៈ ចឹងនៅ3-4ឆ្នាំហើយណាម៉ាក់យាយ
ប៉ុន្តែយាយមកនៅនឹងរហូតតែម្តងរឺក៏ម៉ាក់យាយនៅកន្លែងផ្សេង សិនដែរម៉ាក់យាយ?

ខៈ មុនដំបូងនឹងនៅនោះប៉ុន្តែបានផ្លាស់មកនៅនឹង

កៈ នៅណាវិញម៉ាក់យាយ?
ខៈ នៅផ្ទះតាម៉ុល យាយហ៊ាប

កៈ នៅផ្ទះតាម៉ុល ប៉ុន្តែនៅភ្នំពេញនឹងដែរតើហីម៉ាក់យាយ?

ខៈ នៅភ្នំពេញនឹងតើ!!

កៈ ប៉ុន្តែនៅម្តុំណាដែរទៅម៉ាក់យាយ ដូចថានៅបឹងត្របែករឺមួយក៏ស្ពឺគេចឹងហាស?

ខៈ និយាយរួមទៅគេហៅអីទេនេះខ្ញុំបានភ្លេចបាត់ហើយនឹង

កៈ ចឹងភ្លេចហើយណាម៉ាក់យាយ?

ខៈ ចា៎!នឹងភ្លេចហើយ

កៈ
ប៉ុន្តែម៉ាក់យាយមានបងប្អូនរឺមួយក៏កូនចៅណាដែរទៅរស់នៅក្រៅប្រទេសដែរទេម៉ាក់យាយ?

ខៈ គ្មានទេពូអើយ

កៈ ចឹងមានតែនៅខ្មែរទេណាម៉ាក់យាយ?

ខៈ នៅខ្មែរយើងនឹង

កៈ អ៊ូ!បាទម៉ាក់យាយចុះ?

ខៈ មានតែក្មួយមួយក្មួយមួយណុងនៅថៃ

កៈ គាត់នៅថៃហោស គាត់ធ្វើអីគេដែរនៅថៃម៉ាក់យាយ?

ខ៖ ឈ្មោះអាម៉ុល

ក៖ ប៉ុន្តែគាត់ធ្វើអីគេដែរនៅថៃហាសម៉ាក់យាយ?

ខ៖ គេធ្វើការធ្វើអីនឹងហាស

ក៖ គាត់ធ្វើការសំណង់?

ខ៖ អើរ

ក៖ ប៉ុន្តែគាត់ទៅយូរហើយណាម៉ាក់យាយ?

ខ៖ ទៅយូរដែរហើយនឹងបានធ្វើផ្ទះបានធំណាស់

ក៖ អូ៎!ឡូយ ចុះស្វាមីរបស់ម៉ាក់យាយនឹងគាត់មានឈ្មោះអីគេដែរម៉ាក់យាយ?

ខ៖ គាត់ឈ្មោះឈួន

ក៖ ឈ្មោះឈួន ប៉ុន្តែឈ្មោះអីគេឈួនដែរម៉ាក់យាយ?

ខ៖ ប៉ុន្តែបានស្លាប់ហើយនឹង

ក៖ ប៉ុន្តែឈ្មោះស្អីគេឈួន ដែរម៉ាក់យាយ ត្រកូលរបស់គាត់ហាស?

ខ៖ ឈ្មោះឈួន ឈន ម៉ែឈ្មោះរ៉ាយ

ក៖ អូ៎!បាទនឹងឪពុករបស់គាត់?

ខ៖ ឪពុករបស់គាត់ឈ្មោះឈន

ក៖ ប៉ុន្តែគាត់ឈ្មោះឈួនណាម៉ាក់យាយ?

ខ៖ នឹងហើយ

ក៖
ចឹងសំរាប់ម៉ាក់យាយមានដឹងថាម៉ាក់យាយរៀបអាពាហ៍ពិពាហ៍នៅថ្ងៃខែឆ្នាំណាជាមួយប្ដីរបស់ ម៉ាក់យាយដែរទេ?

ខ៖ ខ្ញុំភ្លេចដែរហើយនឹងពូអើយ
ពួកគាត់នឹងគាត់អ្នករៀបអោយតើមិនដឹងថាថ្ងៃណាថ្ងៃណីទេ

កៈ
ចឹងមិនមែនម៉ាក់យាយជាអ្នករៀបចំដោយខ្លួនឯងទេគឺឪពុកម្ដាយគាត់ជាអ្នករៀបអោយទេចឹង?

ខៈ អើរ

កៈ ប៉ុន្តែកូនរបស់ម៉ាក់យាយសព្វថ្ងៃនឹងគាត់អាយុប៉ុន្មានដែរកូនបងហាស?
ខៈ អាយុ30ឆ្នាំ

កៈ គាត់អាយុ30ឆ្នាំគត់ហោសម៉ាក់យាយ?

ខៈ នឹងហើយ

កៈ ចឹងមានន័យថាម៉ាក់យាយការអស់31ឆ្នាំហើយណាម៉ាក់យាយ?

ខៈ ប៉ុន្តែប្ដីរបស់វានឹងអាយុ40ឆ្នាំហើយនឹង

កៈ អូ៎!ចឹងម៉ាក់យាយការអស់31ឆ្នាំហើយចឹងណាម៉ាក់យាយ?

ខៈ ណុងហើយ

កៈ
អូ៎!បាទចុះកាលពីប្ដីរបស់ម៉ាក់យាយចូលស្ដីដណ្ដឹងម៉ាក់យាយនឹងមានជាជំនូនជូនទៅម៉ាក់យាយដែរ ទេនឹងម៉ាក់យាយ?

ខៈ ជូនជំនូនប៉ុន្មានទេ50ម៉ឺន

កៈ ចឹងម៉ាក់យាយការនៅក្នុងឆ្នាំណាដែរម៉ាក់យាយ?

ខៈ ខ្ញុំមិនសូវដឹងដែរនឹងនេះ ចេះតែភ្លេចភ្លាំងនឹងតាំងពីឈឺនឹងវាភ្លេចភ្លាំងអស់ហើយ

កៈ អូ៎!ចឹងហោសម៉ាក់យាយ ចឹងម៉ាក់យាយការនៅក្នុងឆ្នាំ1987ហោសម៉ាក់យាយ?

ខៈ អើរ

កៈ អូ៎!ចឹងកាលពីជំនាន់ណុងលុយនៅថ្លៃរឺមួយក៏លុយនៅថោកដែរម៉ាក់យាយ?

ខៈ លុយនៅថោកដែរនឹង

កៈ អូ៎!លុយនៅថោកដែរហោសម៉ាក់យាយ ចឹងប្តីរបស់ម៉ាក់យាយនឹងអោយជាជំនូនទៅម៉ាក់យាយបាន ជាង50ម៉ឺនណាម៉ាក់យាយ?

ខៈ ណុងហើយ

កៈ ចុះម៉ាក់យាយមានដឹងថាគាត់ចូលស្តីដណ្តឹងម៉ាក់យាយនៅពេលណាហើយ ហេតុអីបានជាគាត់ស្រលាញ់ម៉ាក់យាយអត់?

ខៈ មានអីទេធម្មតានឹង

កៈ ប៉ុន្តែពីមុននឹងគាត់ធ្លាប់ឃើញមុខម៉ាក់យាយអត់ កាលពីអត់ទាន់ចូលស្តីដណ្តឹងចឹងហាស?

ខៈ នៅច្រូតនឹងទៅច្រូត

កៈ ទៅច្រូតជាមួយគ្នាហោសម៉ាក់យាយ?

ខៈ អត់ទេទៅច្រូតដល់នេះទៅគេរែកកណ្តាប់អោយនឹង

កៈ អូ៎!ចឹងមានន័យថាយើងស្គាល់គ្នាយូរដែរហើយហោសម៉ាក់យាយ?

ខៈ នឹងហើយ

កៈ ហើយបានអោយឪពុកម្តាយចូលស្តីអោយចឹងទៅហោសម៉ាក់យាយ?

ខៈ ចា៎!នឹងហើយ

កៈ ចុះម៉ាក់យាយមានធ្លាប់បានរៀនទេម៉ាក់យាយ?

ខៈ ខ្ញុំរៀនរៀនបានតិចតួចនឹង

កៈ ម៉ាក់យាយរៀនបានថ្នាក់ទីប៉ុន្មានដែរ?

ខៈ ខ្ញុំរៀនបានថ្នាក់ទី2-3នឹង

កៈ រៀនបានថ្នាក់ទី3ហោសចុះកាលពីរៀននឹងម៉ាក់យាយរៀននៅណាដែរទៅម៉ាក់យាយ?

ខៈ រៀននៅសំរោងវាលនឹងរៀននៅវត្តសំរោងវាលនឹង

កៈ ប៉ុន្តែសាលាឈ្មោះអីគេដែរម៉ាក់យាយមានចងចាំអត់
សាលាដែរម៉ាក់យាយរៀនហាសឈ្មោះសាលាហាស?

ខៈ សាលាអីគេនេះនៅក្បែរផ្ទះគ្នានឹងនៅក្បែរវត្តនឹងនៅខាងលិចវត្ត

កៈ អូបាទ ចឹងម៉ាក់យាយមានចេះភាសាអីក្រៅពីភាសាខ្មែរដែរទេម៉ាក់យាយ?

ខៈ អើរ......?

កៈ ម៉ាក់យាយមានចេះភាសាអីផ្សេងក្រៅពីភាសាខ្មែរដែរទេម៉ាក់យាយ?

ខៈ គ្មានចេះទេនឹង

កៈ ចុះភាសាអី?

ខៈ មិនដែររៀនផងនឹងរៀនតែខ្មែរយើងនឹង

កៈ ចុះភាសាវៀតណាម ថៃអីម៉ាក់យាយអត់ចេះទេណាម៉ាក់យាយ?

ខៈ អត់ចេះទេនឹង

កៈ
ម៉ាក់យាយកាលពីក្មេងហាសតើម៉ាក់យាយធ្លាប់មានមិត្តភក្តិជិតស្និទ្ធិណាដែរធំធាត់មកជាមួយគ្នា ដែរទេម៉ាក់យាយកាលនៅរៀនហាស?

ខៈ អើរ....?

កៈ ម៉ាក់យាយធ្លាប់មានមិត្តភក្តិជិតស្និទ្ធិមកជាមួយគ្នាដែរអត់?

ខៈ គ្មានទេ

កៈ អត់មានទេណាម៉ាក់យាយ
ចឹងមិត្តភក្តិដែររៀនជាមួយគ្នានឹងម៉ាក់យាយធ្លាប់មានមិត្តភក្តិដែររៀនមក
ជាមួយគ្នាដែរទេម៉ាក់យាយ?

ខៈ គ្មានទេតែបងប្អូនឯងនឹងទៅរៀនហោស

កៈ អូ៎!ចឹងហោស អូបាទចុះម៉ាក់យាយធ្លាប់ទៅធ្វើការងារនៅវាលស្រែដែរទេ?

ខ៖ វាលស្រែមានតែស្នូងនឹង

ក៖ ចឹងម៉ាក់យាយស្ទូងណាម៉ាក់យាយ?

ខ៖ មានស្ទូងនឹងដកនឹង

ក៖ ប៉ុន្តែម៉ាក់យាយធ្លាប់ទៅធ្វើការងារនៅចំការអត់ចឹង ដូចជាមានជាចំការដែរធ្វើការទេ?

ខ៖ គ្មានទេនឹង

ក៖ អត់មានទេណាម៉ាក់យាយមានតែស្រែទេសំរាប់ដកស្ទូងទេណាម៉ាក់យាយ?

ខ៖ ណុងហើយ

ក៖ អូ៎!បាទម៉ាក់យាយគិតថាតាំងពីក្មេងរហូតមកដល់ឥឡូវនឹងហាស?

ខ៖ ឥឡូវនឹងគេគ្មានស្ទូងទេ ឥឡូវនឹងគេព្រុះ

ក៖ ចឹងគេព្រុះណាម៉ាក់យាយ?

ខ៖ ណុងហើយ

ក៖
ចុះម៉ាក់យាយមានដឹងថាតាំងពីក្មេងនឹងរហូតមកដល់ឥឡូវនឹងហាសម៉ាក់យាយមានធ្លាប់ធ្វើការងារ អីគេខ្លះដែរទៅម៉ាក់យាយ?

ខ៖ ច្រូតហើយរែកពូអើយរែកតែម្នាក់ឯងនឹង

ក៖ អូ៎!ចឹងហោសម៉ាក់យាយ?

ខ៖ ប្ដីស្លាប់ចោលទៅ

ក៖ ចុះម៉ាក់យាយគិតថាតាំងពីក្មេងនឹងម៉ាក់យាយធ្លាប់ការងារអីគេខ្លះដែរទៅ?

ខ៖ គ្មានធ្វើការងារអីទេ មានតែធ្វើការងារស្ទូងដកនឹងពូ

ក៖ រហូតទាល់តែឥឡូវនឹងហោសម៉ាក់យាយ?

ខ៖ រហូតទាល់តែឥឡូវនឹង

កៈ
ប៉ុន្តែឥឡូវនឹងម៉ាក់យាយឈប់ធ្វើហើយមែនម៉ាក់យាយកូននៅចិញ្ចឹមម្តងហីម៉ាក់យាយ?

ខៈ លែងធ្វើហើយនឹងតាំងពីលើសឈាមមកនឹងហាស

កៈ អូ្ហ!ម៉ាក់យាយលើសឈាមហោសម៉ាក់យាយ?

ខៈ ហើយឥឡូវនឹងស្ពឹកជើងស្ពឹងដៃនឹង

កៈ កើតអីបានជាលើសឈាមដែរទៅម៉ាក់យាយ?

ខៈ
ស្ងួតៗនឹងស្រាប់តែតើរពោះឡើងស្ពឹកទាំងអស់នឹងដើរក៏ដើរមិនកើតដែរគេសែងមកផ្ទះម
កនឹង

កៈ ប៉ុន្តែប៉ុន្មានឆ្នាំដែរម៉ាក់យាយ?

ខៈ បីសតែចូលទឹកនឹងស្លាប់ហើយនឹង

កៈ អូ្ហ!ប៉ុន្មានឆ្នាំដែរទៅម៉ាក់យាយ?

ខៈ អស់3ឆ្នាំហើយ

កៈ ចឹងអស់3ឆ្នាំហើយហោសម៉ាក់យាយ ចឹងឥឡូវនឹងម៉ាក់យាយដើរអត់រួចទេ?

ខៈ ដើររួចតិចៗៗដែរនឹង

កៈ ចឹងដើររួចតិចៗៗហោសម៉ាក់យាយ?

ខៈ អើរ

កៈ
អូ្ហ!បាទចឹងចុះម៉ាក់យាយគិតថាម៉ាក់យាយធ្លាប់លក់ដូរវីមួយម៉ាក់យាយធ្លាប់ចិញ្ចឹមសត្វអីដែ
រទេ ម៉ាកយាយ?

ខៈ លក់ដូរនឹងវែកលក់

កៈ លក់អីគេដែរម៉ាក់យាយ?

ខ៖ លក់បន្លែលក់អីនឹង

ក៖ ប៉ុន្តែម៉ាក់យាយមានធ្លាប់ចិញ្ចឹមសត្វទេដូចជាចិញ្ចឹមមាន់ ទា ជ្រូក គោ ក្របីអីបាស?

ខ៖ មានចិញ្ចឹមដែរតើ

ក៖ ចុះម៉ាក់យាយចិញ្ចឹមអីគេដែរម៉ាក់យាយ?

ខ៖ ខ្ញុំចិញ្ចឹមគោ

ក៖ មានចិញ្ចឹមគោច្រើនមែនម៉ាក់យាយ?

ខ៖ ចិញ្ចឹមគោ5ក្បាល

ក៖ អូ្ន!មានគួរសមដែរចឹង?

ខ៖ មានចិញ្ចឹមជ្រូក3ក្បាល

ក៖ អូ្ន!ចឹងមានចិញ្ចឹមមាន់អត់ម៉ាក់យាយ?

ខ៖ មានចិញ្ចឹមមាន់10ក្បាលហោស

ក៖ ចឹងមានចិញ្ចឹមទាអត់ម៉ាក់យាយ?

ខ៖ មានចិញ្ចឹមទា5ក្បាល

ក៖ អូ្ន!ម៉ាក់យាយចិញ្ចឹមច្រើនហោសម៉ាក់យាយចិញ្ចឹមទាំងអស់នឹងចឹង?

ខ៖ អើរ

ក៖ អូបាទ
ចឹងសំរាប់ម៉ាក់យាយគិតថាជីវិតរបស់ម៉ាក់យាយនឹងមានការផ្លាស់ប្តូរអីគេខ្លះដែរម៉ាក់យាយតាំងពីក្មេងរហូតមកដល់ពេលនេះហាសម៉ាក់យាយ?

ខ៖ គ្មានការផ្លាស់ប្តូរអីទេមិនចេះមាត់មិនចេះអីទេនឹង

ក៖ ម៉ាក់យាយមិនសូវចេះមាត់មែនទេម៉ាក់យាយ?

ខ៖ នឹងហើយ

កៈ ចុះជីវភាពអីនឹងម៉េចដែរឥឡូវនឹងហាសម៉ាក់យាយ?

ខៈ ជីវភាពរស់នៅនឹងគ្រាន់បើ

កៈ អូ៎!គ្រាន់បើណាម៉ាក់យាយ ចុះសុខភាពម៉ាក់យាយឥឡូវនឹងយ៉ាងម៉េចដែរទៅ?

ខៈ សុខភាពនឹងដើរស្រួលទេនឹងមិនអីទេ

កៈ ចឹងហោសអូឡូយ ចុះតាំងពីក្មេងនឹងម៉ាក់យាយចូលចិត្តម្ហូបអីគេដែរម៉ាក់យាយដែរម៉ាក់យាយចូលចិត្តពិសារហាស?

ខៈ ចូលចិត្តនឹងចូលចិត្តសាច់ជ្រូក ហើយនឹងត្រី

កៈ ចូលចិត្តសាច់ជ្រូកប៉ុន្តែគេយកទៅធ្វើអីគេដែរម៉ាក់យាយ
យកធ្វើម្ហូបអីគេដែរម៉ាក់យាយចូលចិត្តដែរ ចឹងហាស?

ខៈ គេយកខ ខ្ញុំចូលចិត្តខសំរាប់ខ្ញុំ

កៈ អូ៎!ខ សាច់ជ្រូកហោសម៉ាក់យាយ?

ខៈ ទេ ខ ត្រី

កៈ ប៉ុន្តែដូចជាចៀន ឆា ស្ងោរអីនឹងម៉ាក់យាយចូលចិត្តទេ?

ខៈ ចូលចិត្តដូចតែគ្នានឹង

កៈ អូ៎!ចូលចិត្តដែរហោសម៉ាក់យាយ អូបាទ
ចុះកាលពីនៅក្មេងៗៗនឹងម៉ាក់យាយចូលចិត្តលេងល្បែង ប្រជាប្រិយ៍អីគេដែរម៉ាក់យាយ?

ខៈ មិនដែរទេ

កៈ បោះអង្គុញ ចោលឈូង លាក់កន្សែងអីចឹងហាស?

ខៈ មិនដែរទេលេងតែពេលចូលឆ្នាំនឹង

កៈ ប៉ុន្តែកាលពីនៅក្មេងៗៗនឹងហាសម៉ាក់យាយចូលចិត្តទៅលេងអត់ម៉ាក់យាយ?

ខៈ ចូលចិត្តលេងយីកេលេងអីនឹង

កៈ អូ៎!លេងយីកេណាម៉ាក់យាយចេះលេងយីកេហោសម៉ាក់យាយ?

ខ៖ ចេះតើ!!

ក៖
ចុះមានបងប្អូនរឺមួយក៏សាច់ញាតិណាម្នាក់ចេះលេងឧបករណ៍ភ្លេងដែរទេដូចម៉ាក់យាយហាស?

ខ៖ អ្ហ៎!កាលណុងគេជំនាន់អាពតនឹងគេលេងតិចតួចនឹង

ក៖ អ្ហ៎ៗ!ប៉ុន្តែមានបងប្អូនរបស់ម៉ាក់យាយចេះលេងអត់ លេងយីកេ លេងភ្លេងខ្មែរលេងតន្ត្រីអីអត់?

ខ៖ លេងធ្វើជាយក្សអីនឹង

ក៖ អ្ហ៎!ម៉ាក់យាយជាអ្នកធ្វើហោស?

ខ៖ អត់ទេខ្ញុំដើរតួកំសត់

ក៖ ចុះម៉ាក់យាយធ្វើជាតួចអីគេដែរម៉ាក់យាយ?

ខ៖ ដើរតួកំសត់នឹងហាស

ក៖ ចឹងតួកំសត់តួដែរត្រូវគេវៃនឹងហោសម៉ាក់យាយ?

ខ៖ នឹងហើយ

ក៖ អ្ហ៎!បាទប៉ុន្តែម៉ាក់យាយចូលចិត្តច្រៀងដែរទេ?

ខ៖ អត់ដែរទេ

ក៖ ប៉ុន្តែម៉ាក់យាយចូលចិត្តលេងយីកេ ចូលចិត្តអីចុះល្ខោនអាយៃអីនឹងម៉ាក់យាយចូលចិត្តស្តាប់ដែរទេ?

ខ៖ មានចឹស្តាប់

ក៖ ប៉ុន្តែចំរៀងម៉ាក់យាយចូលចិត្តស្តាប់ដែរទេចឹង?

ខ៖ បើករាល់តែថ្ងៃនឹងគេបើក

ក៖ ចឹងបើកស្តាប់ចំរៀងរាល់ថ្ងៃនឹង
ចុះចំរៀងដែរម៉ាក់យាយចូលចិត្តនឹងបែបលក្ខណះបែបបុរាណ
រឺមួយក៏បែបសម័យដែរម៉ាក់យាយ?

ខ៖ បែបបុរាណនឹង

ក៖ បែបបុរាណណម៉ាក់យាយ
ចុះម៉ាក់យាយគិតថាផ្ទះរបស់ម៉ាក់យាយមានលក្ខណះបែបណាដែរ
តាំងពីក្មេងរហូតមកដល់ពេលនេះហាសម៉ាក់យាយ?

ខ៖ ផ្ទះធំដែរនឹងពូ

ក៖ កាលពីក្មេងនឹងផ្ទះធំដែរហោសម៉ាក់យាយ?

ខ៖ ប៉ុន្តែអាពតវៃខ្ទីចខ្ទីអស់ហើយនឹង គ្មាននៅអីទេ

ក៖ កាលពីនៅព្រៃវែងនឹងហោសម៉ាក់យាយ?

ខ៖ ណុងហើយនឹង

ក៖ ប៉ុន្តែដូចជាឥឡូវនឹងផ្ទះរបស់ម៉ាក់យាយនឹងយ៉ាងម៉េចដែរទៅ?

ខ៖ បាក់បែកអស់ហើយនឹងគេវៃបែកបាក់អស់ហើយនឹង

ក៖ ប៉ុន្តែកាលពីជំនាន់ណុងផ្ទះរបស់ម៉ាក់យាយនឹង
នរណាគេដែរជាអ្នកសាងសងផ្ទះមួយណុងដែរម៉ាក់យាយ?

ខ៖ ឪពុកនឹង

ក៖ ចឹងឪពុករបស់ម៉ាក់យាយ
ប៉ុន្តែដូចជាឪពុករបស់ម៉ាក់យាយជាអ្នកធ្វើផ្ទះមួយននឹងរឺមួយក៏ម៉ាក់យាយ
ចូលជាងមកធ្វើអោយដែរម៉ាក់យាយ?

ខ៖ ជាងជាអ្នកធ្វើនឹង

ក៖ ប៉ុន្តែគាត់អត់ចេះធ្វើផ្ទះទេណម៉ាក់យាយ?

ខ៖ អត់ចេះធ្វើទេចេះតែលក់បន្លែលក់អីនឹងសំរាប់ចិញ្ចឹមក្រុមគ្រួសារ

កៈ អូ!បាទម៉ាក់យាយ ចុះម៉ាក់យាយគិតថាផ្ទះរបស់ម៉ាក់យាយជាថ្ម
រឺជាឈើដែរម៉ាក់យាយ កាលធ្វើ នឹងហាស?

ខៈ ផ្ទះឈើនឹង

កៈ ផ្ទះឈើនឹងហោស ប៉ុន្តែគេមានឧបករណ៍អីគេដែរសំរាប់ធ្វើម៉ាក់យាយមានដឹងទេ?

ខៈ គេធ្វើដែកធ្វើអីនឹង

កៈ មានឈើ មានដែក?

ខៈ នឹងហើយគេលើកខ្ពស់ចឹងទៅ

កៈ
ប៉ុន្តែសំរាប់គេវៃប្រើប្រាស់នឹងឧបករណ៍មានដូចជាដែកគោលនឹងម៉ាក់យាយមានដឹងថា
មានអីទៀតទេ?

ខៈ មានដែកគោលនឹងជញ្ជាំងក្តារ

កៈ បាទមានរណា មានដែកឈូស អីសំរាប់ឈូសចឹងហាសណាម៉ាក់យាយ?

ខៈ ណុងហើយផ្ទះនៅមាំដែរខំតែអាពតនឹងវាវៃចោលនឹង

កៈ បាទម៉ាក់យាយចុះម៉ាក់យាយគិតថាមានជំនាញអីគេដែរម៉ាក់យាយគិតថាម៉ាក់យាយ
ចេះស្ទាត់ជំនាញដែរចឹងហាស?

ខៈ មានជំនាញអីទេនេះ

កៈ ម៉ាក់យាយពូកែអីគេដែរម៉ាក់យាយដកស្ទូង នឹងលក់ដូរអីចឹងហាស?

ខៈ មួយភ្លេតមួយផ្លូនៗនេះ

កៈ ចឹងហោសចឹងម៉ាក់យាយពូកែខាង?

ខៈ ពូកែខាងដកស្ទូងនឹង

កៈ ចឹងខាងដកស្ទូង
ចឹងសំរាប់ឪពុកម្តាយរបស់ម៉ាក់យាយនឹងគាត់មានធ្លាប់បង្រៀនពីជំនាញអីទៅ

ម៉ាក់យាយដែរទេដូចលក្ខណៈថាវេញវល្លិ៍ កូវស្កុរត្នោត ធ្វើកន្ទេលអញ្ចូត
ធ្វើផ្តៅធ្វើអីចឹងហាស?

ខ៖ អត់ដែរទេអត់ដែរចេះធ្វើទេ

ក៖ សូម្បីតែកន្ទេលអញ្ចូតក៏ម៉ាក់យាយមិនចេះដែរ?

ខ៖ អត់ទេទិញគេ

ក៖ ចឹងម៉ាក់យាយទិញគេ ចុះល្អីហោសម៉ាក់យាយ?

ខ៖ ទិញគេរហូតនឹង

ក៖ អូ៎!បាទចុះម៉ាក់យាយអាចប្រាប់ពីពេលដែរលំបាកនៅក្នុងជីវិតរបស់ម៉ាក់យាយបានទេ
ម៉ាក់យាយធ្លាប់មានការលំបាកអីគេនៅក្នុងជីវិតរបស់ម៉ាក់យាយដែរចឹងហាស?

ខ៖ នៅក្មេងនឹងពិបាកណាស់ពូអើយ

ក៖ ធ្វើអីគេខ្លះដែរទៅម៉ាក់យាយ?

ខ៖ ដើរស៊ីឈ្នួលគេយកមកចិញ្ចឹមជីវិត

ក៖ អូ៎!ប៉ុន្តែយើងដើរជាមួយបងប្អូននឹងឪពុកម្តាយដែរតើហីម៉ាក់យាយ?

ខ៖ លក្ខណៈស្គាល់ៗៗគ្នាដែរ

ក៖ អូ៎!ប៉ុន្តែស៊ីឈ្នួលធ្វើអីគេដែរទៅម៉ាក់យាយ?

ខ៖ ស៊ីឈ្នួលស្ទូង

ក៖ ទៅស្ទូងអោយគេហោស ប៉ុន្តែយើងមានស្រែខ្លួនឯងដែរតើហីម៉ាក់យាយ?

ខ៖ ស្រែនឹងស្ទូងរបស់ឯងហើយនឹងបានដើរស៊ីឈ្នួលគេ

ក៖ បាទម៉ាក់យាយដូចជា?

ខ៖ អង្គុយយូរពេកនឹងខ្ញុំទៅផ្ទះហើយ

ក៖
អូ៎!ចឹងហោសម៉ាក់យាយចឹងខ្ញុំអាចសុំមួយសំនួរទៅពីរសំនួរទៀតចប់ហើយម៉ាក់យាយ?

ខ៖ អើរ

ក៖ ចុះម៉ាក់យាយមានធ្លាប់មានក្តីស្រម៉ៃថាកាលពីម៉ាក់យាយនៅក្មេងហាស ម៉ាក់យាយចង់ធ្វើអីគេដែរនៅពេលដែរម៉ាក់យាយធំឡើងអីចឹងហាសម៉ាក់យាយធ្លាប់មានក្តីស្រម៉ៃទេ?

ខ៖ ចង់កាត់ដេរ

ក៖ ចង់កាត់ដេរ
ចុះតាំងពីក្មេងម៉ាក់យាយគិតថាធ្លាប់មានជួបការសប្បាយអីគេខ្លះដែរចឹងម៉ាក់យាយ?

ខ៖ សប្បាយដែរ

ក៖ មានសប្បាយធ្វើអីគេខ្លះដែរចឹងហាសម៉ាក់យាយ លក្ខណះការចៅរឺក៏ការកូន រឺក៏ការខ្លួនឯងចឹងហាស?

ខ៖ នឹងហើយការកូន ការកូននឹងសប្បាយបានកូនរៀបហើយនឹង

ក៖
ចុះម៉ាក់យាយគិតថាម៉ាក់យាយឆ្លងកាត់ការលំបាកនឹងដោយរបៀបណាជំនះឧបសគ្គដោយរបៀប ណាចឹងហាសម៉ាក់យាយ?

ខ៖ ការកូនហើយនឹងធូរហើយពូអើរ

ក៖ ចុះម៉ាក់យាយខ្ញុំមានសំនួរចុងក្រោយចង់សួរថា
បើសិនជាចង់អោយម៉ាក់យាយផ្តែផ្តាំទៅកូនចៅ
ជំនាន់ក្រោយៗៗហាសម៉ាក់យាយចង់ផ្តែផ្តាំអីទៅពួកគាត់ដែរម៉ាក់យាយ?

ខ៖ អត់ដឹងទេនេះខ្ញុំមិនចេះផងនឹង

ក៖ ប៉ុន្តែម៉ាក់យាយគិតថាអោយគាត់ខំប្រឹងរៀនសូត្រ?

ខ៖ នឹងហើយអោយគាត់ខំប្រឹងរៀនសូត្រប៉ុណ្ណឹងទេ

ក៖ នឹងអោយពួកគាត់មានការងារល្អណាម៉ាក់យាយ?

ខ៖ នឹងហើយ

កៈ
ចុះបើសិនជាចង់អោយពួកគាត់ជៀសវៀងវិញតើម៉ាក់យាយចង់អោយពួកគាត់ជៀសវៀងអីគេដែរ ចឹងហាសម៉ាក់យាយ?

ខៈ ជៀសវៀងពីគ្រឿងញៀន

កៈ ជៀសវៀងពីគ្រឿងញៀន
ចុះមានអីផ្សេងទៀតអត់ម៉ាក់យាយដែរម៉ាក់យាយគិតអោយពួកគាត់ជៀសវៀងហាស?

ខៈ នឹងហើយ

កៈ មានអីផ្សេងដែរម៉ាក់យាយគិតថាចង់អោយពួកគាត់ជៀសវៀងទៀតទេ?

ខៈ ជៀសវៀងពីគ្រឿងញៀននឹងមិនកើតទេ

កៈ វាអត់ល្អទៅដល់សង្គមណាម៉ាក់យាយ?

ខៈ អត់ល្អនឹងហើយ អត់ល្អទេពូ?

កៈ
ចុះមនុស្សផឹកស្រាវីមួយផឹកអីចឹងដែរស្រវឹងហាសម៉ាក់យាយចង់ផ្ដែផ្ដាំអោយពួកគាត់ធ្វើអីគេដែរ ទៅម៉ាក់យាយ?

ខៈ តែស្រវឹងនឹងគេធ្វើបាបយើងហើយនឹងមនុស្សប្រុសនឹង

កៈ អូ៎!បាទកុំអោយបើកបរកុំអោយអីចឹងហោសម៉ាក់យាយ?

ខៈ នឹងហើយនឹង

កៈ
អូ៎!បាទចុះម៉ាក់យាយមានចង់អោយកូនចៅអោយរីកចំរើននៅក្នុងសង្គមនឹងក្នុងក្រុមគ្រួសារអីចឹង ហាស?

ខៈ អើរ

កៈ
បាទចឹងជាចុងក្រោយខ្ញុំអរគុណច្រើនម៉ាក់យាយដែរបានផ្ដល់ប្រវត្តិរបស់ម៉ាក់យាយអោយ

ខ្ញុំចឹង
ហាសម៉ាក់យាយហើយនៅពេលដែរខ្ញុំបានពិភាក្សាជាមួយម៉ាក់យាយនឹងខ្ញុំនឹងដាក់ការសំ
ភាសន៍ដែរខ្ញុំ បានពិភាក្សាជាមួយម៉ាក់យាយនឹងទៅដាក់ក្នុងវេបសាយរបស់សាលា
ដើម្បីអោយគេអាចទុករក្សាអោយ កូនចៅរបស់ម៉ាក់យាយ
ហើយនឹងអាចអោយពួកគាត់នឹងបានដឹងពីប្រវត្តិរបស់ម៉ាក់យាយ
នឹងឪពុកម្តាយរបស់ម៉ាក់យាយដែរម៉ាក់យាយបានរៀបរាប់មិញចឹង
ហើយនឹងបានកូនដែរបានស្គាល់ចឹង ហាសម៉ាក់យាយ
បាទចឹងអរគុណច្រើនដែរម៉ាក់យាយ៕៕៕